# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៩-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៤ តម្លើងឋានន្តរសក្តិ ឧត្តមសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព ឧត្តមសេនីយ៍ទោ សេ សារឿ | ១៣៦ |
| ២២-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៥ តែងតាំង ឯកឧត្តម ស្រ៊ី ថាមរុទ្ធ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | ១៣៧ |
| ២២-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៦ តម្លើងឋានៈជូន ឯកឧត្តម នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ចំនួន ០៦រូប មានឋានៈ ស្មើ អនុរដ្ឋលេខាធិការ | ១៣៨ |
| ២២-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៧ តម្លើងឋានៈជូន លោកជំទាវ សុខ ឡេងម៉ូវ៉ា នាយិកាពិធីការ សម្តេចនាយករដ្ឋមន្ត្រី មានឋានៈ ស្មើ អនុរដ្ឋលេខាធិការ | ១៣៩ |
| ២២-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៨ តម្លើងឋានៈជូន ឯកឧត្តម លោកជំទាវជំនួយការ សម្តេចនាយករដ្ឋមន្ត្រី ចំនួន ១៧រូប មានឋានៈ ស្មើ អគ្គនាយក | ១៤០ |
| ២២-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៩ តម្លើងឋានៈជូន ឯកឧត្តម ជំនួយការសម្តេចនាយករដ្ឋមន្ត្រី ចំនួន ០៦រូប មានឋានៈស្មើ អគ្គនាយក | ១៤១ |
| ២២-០១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០១០១/០២០ តែងតាំង និងតម្លើងឋានន្តរសក្តិជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី ជូនឯកឧត្តម ហេង សារឿន , ឯកឧត្តម សុខ សុខៈ | ១៤២ |

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ


២២-០១-២០០១ -អនុក្រឹត្យ លេខ០៦ អនក្រ-បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកណ្តាល ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ ១៤៤

២២-០១-២០០១ -អនុក្រឹត្យ លេខ០៧ អនក្រ-បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តតាកែវ ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ ១៤៧

២២-០១-២០០១ -អនុក្រឹត្យ លេខ០៨ អនក្រ-បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកំពង់ឆ្នាំង ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ ១៥០

២២-០១-២០០១ -អនុក្រឹត្យ លេខ០៩ អនក្រ-បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តពោធិសាត់ ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ ១៥៣

២២-០១-២០០១ -អនុក្រឹត្យ លេខ១០ អនក្រ-បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តសៀមរាប ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ ១៥៥

១៦-០១-២០០១ -អនុក្រឹត្យ លេខ២៤ អនក្រ-តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៨

១៨-០១-២០០១ -អនុក្រឹត្យ លេខ២៥ អនក្រ-តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៩

២២-០១-២០០១ -អនុក្រឹត្យ លេខ២៦ អនក្រ-តត ស្តីពីការជូនមេដាយការងារ ១៦០

២២-០១-២០០១ -អនុក្រឹត្យ លេខ២៧ អនក្រ-តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១

២២-០១-២០០១ -អនុក្រឹត្យ លេខ២៨ អនក្រ-តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦៣

២២-០១-២០០១ -អនុក្រឹត្យ លេខ២៩ អនក្រ-តត ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហាន ១៦៦

២៣-០១-២០០១ -អនុក្រឹត្យ លេខ៣០ អនក្រ-តត ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ ១៦៧

## ២-សេចក្តីសំរេច

១៦-០១-២០០១ -សេចក្តីសំរេច លេខ២០៤ សសរ ស្តីពីការ ប្រគល់ទីតាំងដី និងអាគារ សាលាមធ្យមសិក្សាពាណិជ្ជកម្ម និងមជ្ឈមណ្ឌលកូឡាបទី៣ ១៦៨

១៨-០១-២០០១ -សេចក្តីសំរេច លេខ២០៥ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ការនាំចូលតាមច្រកព្រំដែន នូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគ ដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ ១៦៩

១៨-០១-២០០១ -សេចក្តីសំរេច លេខ២០៦ សសរ ស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការ អភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា វៀតណាម ឡាវ ១៧២

## ៣-សារាចរណែនាំ

១៦-០១-២០០១ -សារាចរណែនាំ លេខ ០១ សរណន ស្តីពីការរៀបចំបែបបទស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ១៧៥

# II-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សេចក្តីប្រកាស

២២-០១-២០០១ -សេចក្តីប្រកាស លេខ ០២២ សប្រក.កសក ស្តីពីការហាមឃាត់សកម្មភាពអាជីវកម្ម ពាណិជ្ជកម្មព្រៃឈើ ការកាន់កាប់រានដីព្រៃ និងការបរបាញ់សត្វព្រៃក្នុងតំបន់ជួរភ្នំក្រវាញ ភាគកណ្តាល ១៨០

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៤

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១

### ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរសក្តិ **ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព ឧត្តមសេនីយ៍ទោ **រស់ សារុំ** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន កិច្ចការនយោបាយរដ្ឋបាល និងនគរបាលជាតិ នៃក្រសួង មហាផ្ទៃ ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ**

**និកពោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- **បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី ១៨ ខែ មករា ឆ្នាំ ២០០១**

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំងជាទីប្រឹក្សាផ្ទាល់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

-ឯកឧត្តម **ស្រី ថាមរុទ្ធ**

-ឯកឧត្តម **ស៊ាន ម៉ូរ៉ាត**

**មាត្រា ២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៦

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- **បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី ១៨ ខែ មករា ឆ្នាំ ២០០១**

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតម្លើងឋានៈ ជូនឯកឧត្តមនាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈ ស្មើ **អនុរដ្ឋលេខាធិការ** ចំនួន ០៦រូប ដូចមានរាយនាមខាងក្រោម :

-ឯកឧត្តម **មុត ខៀវ** -ឯកឧត្តម **គឹម ម៉ិនថាន**

-ឯកឧត្តម **ប្រាក់ វណ្ណឌី** -ឯកឧត្តម **ហ៊ីង ម៉ិនហៀង**

-ឯកឧត្តម **រស់ កុសល** -ឯកឧត្តម **ខ៉ែត បូរី**

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអោយបាន សំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

---

## ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## ជមហាវិរបុរុស ឧត្តមសោភ័ណ្ឌ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី ១៨ ខែ មករា ឆ្នាំ ២០០១

**ព្រះរាជក្រឹត្យ**

**មាត្រា ១** .- ត្រូវបានតម្លើងឋានៈ ជូនលោកជំទាវ **ឡុងសេង ម៉ូរ៉ា** នាយិកាពិធីការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី ១៨ ខែ មករា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១** .- ត្រូវបានតម្លើងឋានៈ ជូនឯកឧត្តម លោកជំទាវ ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈ ស្មើ **អគ្គនាយក** ចំនួន ១៧រូប ដូចមានរាយនាមខាង ក្រោម :

-ឯកឧត្តម **ស៊ូ ស៊ីម**
-ឯកឧត្តម **លឹម លាងសែ**
-ឯកឧត្តម **ហ៊ុន ស៊ីថា**
-ឯកឧត្តម **ម៉ែន រុន**
-ឯកឧត្តម **ស៊ូ ណារ៉ូ**
-លោកជំទាវ **កែត ឌុល**
-ឯកឧត្តម **សាម៉ឺឌី ស៊ីវឡៃនា**
-ឯកឧត្តម **ដាវ សារី**
-ឯកឧត្តម **តាន់ បញ្ញាវុធ**
-ឯកឧត្តម **សួន រចនា**
-ឯកឧត្តម **កែប ចុងហ៊ាង**
-ឯកឧត្តម **អ៊ាង សុផល្លែត**
-ឯកឧត្តម **ហ៊ុន ហេង**
-ឯកឧត្តម **ហាច ប៊ុនសែ**
-ឯកឧត្តម **ឡុង ផុល**
-ឯកឧត្តម **ម៉ិន នោ**
-ឯកឧត្តម **ចៅ តុល**

**មាត្រា ២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

---

**ព្រះរាជក្រឹត្យ នស/រកត/០១០១/០១៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី ១៨ ខែ មករា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតម្លើងឋានៈ ជូនឯកឧត្តម ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ចំនួន ០៦រូប ដូចមានរាយនាមខាងក្រោម :

-ឯកឧត្តម **ទេព្យ ទិសុត** -ឯកឧត្តម **ហង់ជួន ណារ៉ុន**

-ឯកឧត្តម **ម៉ូល ពីខូ** -ឯកឧត្តម **ចាន់ សុធី**

-ឯកឧត្តម **គឹម សុគៈ** -ឯកឧត្តម **ម៉ុក ធារី**

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

---

## ព្រះរាជក្រឹត្យ នស/រកត/០១០១/០២០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពល ខេមរភូមិន្ទ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី ១៨ ខែ មករា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំងនិងតម្លើងឋានន្តរសក្តិ ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក និងជាឧត្តមសេនីយ៍ត្រី នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

-ឯកឧត្តម **ហេង សាវឿន**

-ឯកឧត្តម **សុខ សុខៈ**

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# II-រាជរដ្ឋាភិបាលកម្ពុជា

## ១-អនុក្រឹត្យ

## អនុក្រឹត្យ លេខ ០៦ អនក្រ.បក

## ស្តីពី

## ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកណ្តាល ទុកសំរាប់ប្រជាពលរដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តកណ្តាលដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទបឹងព្រែក លេខ ២ . ១៣. ១៤ និងលេខ ១៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តកណ្តាល និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកណ្តាល ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ បឹងព្រែក | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ៨ ៧៧២ | ៦ ៣២២ | ២ ៤៥០ | ៧២ ០០ | |
| ២ | ១៧ ២៥០ | ១៧ ២៥០ | ០ | ១០០ | លុបចោល |
| ៣ | ១២ ៨៦៩ | ១០ ១៥២ | ២ ៧១៧ | ៧៨ ៨៨ | |
| ៤ | ៩ ៦៤៨ | ៧ ៥១៥ | ២ ១៣៣ | ៧៧ ៩០ | |
| ៥ | ១០ ៥៩៦ | ៧ ៦៥៤ | ២ ៩៤២ | ៧២ ២៣ | |
| ៦ | ២៧ ៥៨០ | ១៨ ៣០០ | ៩ ២៨០ | ៦៦ ៣៥ | |
| ៧ | ៧ ៨៧០ | ៧ ០០៣ | ៨៦៧ | ៨៨ ៩៨ | |
| ៨ | ២ ៤០៥ | ១ ៨២៤ | ៥៨១ | ៧៥ ៨៤ | |
| ៩ | ៧ ១៦២ | ៤ ៩៨៥ | ២ ៥៧៧ | ៦៤ ០០ | |
| ១០ | ៣ ៧៦៨ | ១ ៣៣៤ | ២ ៤៣៤ | ៣៥ ៤០ | |
| ១១ | ៦ ៦៩៧ | ២ ៩១១ | ៣ ៧៨៦ | ៤៣ ៤៦ | |
| ១២ | ៩ ៨៤៩ | ៤ ១៦៧ | ៥ ៦៨២ | ៤២ ៣០ | |
| ១៣ | ៣ ៩២២ | ៣ ៩២២ | ០ | ១០០ | លុបចោល |
| ១៤ | ៦ ៤៥០ | ៦ ៤៥០ | ០ | ១០០ | លុបចោល |
| ១៥ | ១ ៥៥២ | ១ ៥៥២ | ០ | ១០០ | លុបចោល |
| ១៦ | ១២ ៣២២ | ៧ ៧៣៧ | ៤ ៥៨៥ | ៦២ ៧៩ | |
| ១៧ | ៩ ០៨៤ | ៦ ២៤៧ | ២ ៨៣៧ | ៦៨ ៧៦ | |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ១២ ៨២៩ | ៧ ៣២៧ | ៥ ៥០២ | ៥៧ ១១ | |
| ១៩ | ៩ ៥០៣ | ៦ ២៣៦ | ៣ ២៦៧ | ៦៥ ៦២ | |
| សរុប ១៩ | ១៧៩ ៧២៨ | ១២៨ ០៨៨ | ៥១ ៦៤០ | ៧១ ២៦ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហួងហែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ០៧ អនក្រ.បក

## ស្តីពី

## ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តតាកែវ ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តតាកែវ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ ២ . ៣. ៤ .៦ . ៧. ៨. ៩. ១០. ១៣. ១៧ និងលេខ ១៩ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តតាកែវ និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូតិ៍នេសាទក្នុងខេត្តកណ្តាល ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ឈ្មោះ និងលេខឡូតិ៍ ចំការ | ផ្ទៃឡូតិ៍ នេសាទ | ផ្ទៃឡូតិ៍ កាត់ចេញ | ផ្ទៃឡូតិ៍ នៅសល់ | ផ្ទៃឡូតិ៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ២ ៨៣៦ | ២៤ | ២ ៨១២ | ០.៨ | |
| ២ | ១ ៧៣៣ | ១ ៧៣៣ | ០ | ១០០ | លុបចោល |
| ៣ | ៩៥១ | ៩៥១ | ០ | ១០០ | លុបចោល |
| ៤ | ២ ១០៥ | ២ ១០៥ | ០ | ១០០ | លុបចោល |
| ៥ | ៣៩៤ | ០ | ៣៩៤ | ០ | |
| ៦ | ១ ២២៣ | ១ ២២៣ | ០ | ១០០ | លុបចោល |
| ៧ | ១ ១៤៨ | ១ ១៤៨ | ០ | ១០០ | លុបចោល |
| ៨ | ៦៣០ | ៦៣០ | ០ | ១០០ | លុបចោល |
| ៩ | ១ ២២១ | ១ ២២១ | ០ | ១០០ | លុបចោល |
| ១០ | ១ ៧៦០ | ១ ៧៦០ | ០ | ១០០ | លុបចោល |
| ១១ | ១ ៣៦៩ | ០ | ១ ៣៦៩ | ០ | |
| ១២ | ៩០២ | ០ | ៩០២ | ០ | |
| ១៣ | ៣ ៩២២ | ៣ ៩២២ | ០ | ១០០ | លុបចោល |
| ១៤ | ៧ ៩៧៤ | ២ ៤៦១ | ៥ ១១៣ | ៣២ ៤៩ | |
| ១៥ | ២ ៦៣៦ | ០ | ២ ៦៣៦ | ០ | |
| ១៦ | ២ ០៨៣ | ១ ០២៣ | ១ ០៦០ | ៤៩ ១១ | |
| ១៧ | ១ ៨៩៧ | ១ ៨៩៧ | ០ | ១០០ | លុបចោល |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ៩១៩ | ០ | ៩១៩ | ០ | |
| ១៩ | ៤ ០៧៩ | ៤ ០៧៩ | ០ | ១០០ | លុបចោល |
| ២០ | ៦ ៦៧៣ | ១ ៩០៨ | ៤ ៧៦៥ | ២៨ ៥៩ | |
| សរុប ២០ | ៤៦ ០០៧ | ២៦ ០៤១ | ១៩ ៩៦៦ | ៥៦ ៦០ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ដោយដាច់ខាតមិនអោយជនណាមួយហួងហែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ០៨ អនក្រ.បក
## ស្តីពី
## ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកំពង់ឆ្នាំង ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តកំពង់ឆ្នាំង ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ ៧ . ១៣. ១៤ .១៥ . ១៨. ១៩. និងលេខ ២០ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តកំពង់ឆ្នាំង និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកំពង់ឆ្នាំង ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៧ ៨៥១ | ០ | ៧ ៨៥១ | ០ | |
| ២ | ៣ ៥២៨ | ២២០ | ៣ ៣០៨ | ៦.២៣ | |
| ៣ | ៥២៩ | ០ | ៥២៩ | ០ | |
| ៤ | ២ ៤៤៧ | ៧៤៧ | ១ ៧០០ | ៣០.៥២ | |
| ៥ | ៤ ៧១៨ | ១៩៣ | ៤ ៥២៥ | ៤.០០ | |
| ៦ | ៥ ៦១៣ | ២៣៤ | ៥ ៣៧៩ | ៤.១៦ | |
| ៧ | ២១៣ | ២១៣ | ០ | ១០០ | លុបចោល |
| ៨ | ២ ១៣០ | ២២ | ២ ១០៨ | ១.០០ | |
| ៩ | ៤០៧ | ៧៦ | ៣៣១ | ១៨. ៦៧ | |
| ១០ | ១៦ ៩៥១ | ៨៣២ | ១៦ ១១៩ | ៤.៩០ | |
| ១១ | ២ ២៨៥ | ៥ | ២ ២៨០ | ០.២១ | |
| ១២ | ៥៥៣ | ១៨២ | ៣៧១ | ៣២ .៩១ | |
| ១៣ | ១ ៨៧៤ | ១ ៨៧៤ | ០ | ១០០ | លុបចោល |
| ១៤ | ២ ៣១៥ | ២ ៣១៥ | ០ | ១០០ | លុបចេញ |
| ១៥ | ៥ ៦៥៤ | ៥ ៦៥៤ | ០ | ១០០ | លុបចេញ |
| ១៦ | ៧៥៣ | ៥៧០ | ១៨៣ | ៧៥.៦៩ | |
| ១៧ | ១៧០ | ១៧០ | ០ | ១០០ | លុបចោល |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ២ ៤៣៨ | ២ ៤៣៨ | ០ | ១០០ | លុបចេញ |
| ១៩ | ១ ៤២៧ | ១ ៤២៧ | ០ | ១០០ | លុបចោល |
| សរុប ១៩ | ៦២ ២៥៦ | ១៧ ១៧២ | ៤៥ ០៨៤ | ២៧.៥៨ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុងហ៊ែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

# អនុក្រឹត្យ លេខ ០៩ អនក្រ.បក
# ស្តីពី
# ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តពោធិ៍សាត់ ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តពោធិសាត់ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ ៤ និងលេខ ៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តពោធិសាត់ និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តពោធិសាត់ ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៦ ៨៩៩ | ២ ៨៣៧ | ៤ ០៦២ | ៤១.១២ | |
| ២ | ១៣ ០០៥ | ៥ ៥២៩ | ៧ ៤៧៦ | ៤២ .៥១ | |
| ៣ | ៧ ៦៥៥ | ៣ ៣៥៩ | ៤ ២៩៦ | ៤៣ .៨៧ | |
| ៤ | ៧ ០១៧ | ៧ ០១៧ | ០ | ១០០ | លុបចោល |
| ៥ | ៨ ២១២ | ៨ ២១២ | ០ | ១០០ | លុបចោល |
| ៦ | ៦ ៤៨៩ | ០៩០ | ៥ ៥៨០ | ១៤ .០០ | |
| ៧ | ៥ ៨៤៣ | ២ ៤០៩ | ៣ ៤៣៤ | ៤១ .២២ | |
| សរុប ៧ | ៥៥ ១២០ | ៣០ ២៧២ | ២៤ ៨៤៨ | ៥៤ .៩២ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុំព័ទ្ធហែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

បានចុះហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ១០ អនក្រ.បក

# ស្តីពី

# ការលុបនាតីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាតីឡូត៍នេសាទ ខេត្តសៀមរាប ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- **បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## សំរេច

**មាត្រា ១ ៈ**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តសៀមរាប ដូចតទៅ ៖

- លុបចេញនាទីឡូត៍នេសាទបឹងព្រៃក លេខ ១. ២. ៣ និងលេខ ៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តសៀមរាប និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តសៀមរាប ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| **បឹងព្រៃក** | | | | | |
| ១ | ៦ ៩៧៣ | ៦ ៩៧៣ | ០ | ១០០ | លុបចេញ |
| ២ | ៥ ១៣៤ | ៥ ១៣៤ | ០ | ១០០ | លុបចេញ |
| ៣ | ៧ ៨៨០ | ៧ ៨៨០ | ០ | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ៤ ៨០៨ | ២ ៤៨៣ | ២ ៣២៥ | ៥១ ៦៤ | |
| ៥ | ៨ ៤៨៣ | ៨ ៤៨៣ | ០ | ១០០ | លុបចោល |
| ៦ | ៣១ ២៣២ | ១៩ ២៨៣ | ១១ ៩៤៩ | ៦១ .៧៤ | |
| ៧ | ១៩ ៤៣១ | ១០ ៩៨០ | ៨ ៤៥១ | ៥៦ .៥០ | |
| សរុប ៧ | ៨៣ ៩៤១ | ៦១ ២១៦ | ២២ ៧២៥ | ៧២ .៩២ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុងហែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ២៤ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

~~~

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់ក្រសួងអប់រំយុវជន និងកីឡា

## សំរេច

**មាត្រា ១ .-** តែងតាំងមន្ត្រីថ្នាក់នាយកដ្ឋាន ចំនួន០៣រូប របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម :

១-លោក **ច្រឹង លឹមស្រ៊ី** ជាប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

២-លោក **ឡោ ឡាក់** ជាប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិ

៣-លោក **យក់ ឌុំយ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**មាត្រា ៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ
~~~

ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

**អនុក្រឹត្យ លេខ ២៥ អនក្រ.តត**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

~~~

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រប.ក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពត៌មាន
- យោងតាមសំណើរបស់ក្រសួងពត៌មាន

**សំរេច**

**មាត្រា ១ .-** តែងតាំងលោក **ចាន់ គឹមសា** ជាអគ្គនាយករង នៃទីភ្នាក់ងារសារពត៌មានកម្ពុជា AKP របស់ក្រសួង ពត៌មាន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ
~~~

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

# អនុក្រឹត្យ លេខ ២៦ អនក្រ.តត

# ស្តីពី

## ការផ្តល់មេដាយការងារ

~~~

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

### សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការខេត្តសៀមរាប ០៤រូប ដែល មានស្នាដៃល្អក្នុងការជួយកសាងស្ពានវត្តរាជបូព៌ា ដូចមានរាយនាមខាងក្រោមនេះ :

**ក.-មេដាយមាសការងារ :**

-ឯកឧត្តម **ម៉ិច សុខិន** អភិបាលរងទី៣ ខេត្ត
~~~

**ខ-មេដាយប្រាក់ការងារ**

១-ឯកឧត្តម **សុខ ស៊ុនលីន** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត

២-ឯកឧត្តម **លួន អាន** ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ខេត្ត

**គ-មេដាយសំរិទ្ធការងារ :**

-ឯកឧត្តម **ឡុយ ហួយ** អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ភ្នំពេញ.ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈ ≈ ≈

## អនុក្រឹត្យ លេខ ២៧ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

—

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន នៅក្នុង និងក្រៅប្រទេស ១៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជាថវិកាចូលរួមជួយកសាងហេដ្ឋារចនាសម្ព័ន្ធនៅ ក្នុងស្រុកក្រឡាញ់ និងស្រុកសូត្រនិគម ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោមនេះ :

**ក.មេដាយមាសស្ថាបនាជាតិ :**

| | |
|---|---|
| ១-លោក **អ៊ុំ តូច** | ទឹកប្រាក់ ចំនួន ១៧ ២២១ ដុល្លារអាមេរិក |
| ២-លោក **គោស៊ឺ សារឿត** | ទឹកប្រាក់ ចំនួន ១៥ ៦៨០ ដុល្លារអាមេរិក |
| ៣-លោក **ឡោ ហ៊ត់ស៊ុយ** | ទឹកប្រាក់ ចំនួន ១១ ៥០០ ដុល្លារអាមេរិក |
| ៤-អ្នកស្រី **ខាំ ផល្លី** | ទឹកប្រាក់ ចំនួន ១០ ០០០ ដុល្លារអាមេរិក |
| ៥-អ្នកស្រី **លោម គឹមជួ** | ទឹកប្រាក់ ចំនួន ១០ ០០០ ដុល្លារអាមេរិក |

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | |
|---|---|
| ១-លោក **តាន់ ថាយ** | ទឹកប្រាក់ ចំនួន ២ ០០០ ដុល្លារអាមេរិក |
| ២-លោក **រិត អ៊ាន** | ទឹកប្រាក់ ចំនួន ២ ០០០ ដុល្លារអាមេរិក |
| ៣-លោកយាយ **គឹម ឃុន** | ទឹកប្រាក់ ចំនួន ១ ៥០០ ដុល្លារអាមេរិក |
| ៤-លោក **ពេជ្រ សំប៊ុន** និងអ្នកស្រី **លី គឹមរ៉េត** | ទឹកប្រាក់ចំនួន ១ ០៨០ ដុល្លារអាមេរិក |
| ៥-លោក **សោ ទិសិដ្ឋ** | ទឹកប្រាក់ ចំនួន ១ ០០០ ដុល្លារអាមេរិក |
| ៦-អ្នកស្រី **សៅ ស្រីពៅ** | ទឹកប្រាក់ ចំនួន ១ ០០០ ដុល្លារអាមេរិក |
| ៧-លោកយាយ **តាន់ ស៊ត់** | ទឹកប្រាក់ ចំនួន ១ ០០០ ដុល្លារអាមេរិក |
| ៨-លោកស្រី **តាន់ គឹមលីន** | ទឹកប្រាក់ ចំនួន ១ ០០០ ដុល្លារអាមេរិក |
| ៩-លោក **សៀវ បេងលី** | ទឹកប្រាក់ ចំនួន ១ ០០០ ដុល្លារអាមេរិក |

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

# អនុក្រឹត្យ លេខ ២៨ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

**សំរេច**

**មាត្រា ១** .- ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស២៣រូប ដែលបានឧបត្ថម្ភ ថវិកាក្នុងការជួយកសាងសង់ស្ពាន វត្តរាជបូព៌ ក្នុងខេត្ត សៀមរាប ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

**ក. មេដាយមាសស្ថាបនាជាតិ :**

១-ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃរាជ គណមហានិកាយនៃកម្ពុជា

២-ព្រះសុមង្គលសីលាចារ្យ **ពុធ ម៉ុណា** ព្រះមេគណខេត្ត វត្តកេសរារាម ខេត្តសៀមរាប

៣-ព្រះមហាវិមលធម្ម **ពិន សែម** សេរីសុវណ្ណោ វត្តរាជបូព៌ ខេត្តសៀមរាប

៤-ព្រះញាណកោសល **ខៀវ ណើយ** បញ្ញាវិសាលោ វត្តរាជបូព៌ ខេត្តសៀមរាប

៥-ព្រះតេជគុណ **ពេជ្រ សន** ធម្មធរគណខេត្ត និងអនុគណ ស្រុកសៀមរាប

៦-ឯកឧត្តម **ស ខេង** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ទឹកប្រាក់ ៣០ ០០០ដុល្លារអាមេរិក

៧-ឯកឧត្តម **ស៊ី សំណាង** អគ្គនាយកភស្តុភា ក្រសួងការពារជាតិ ស៊ីម៉ង់ត៍

២ ៥០០តោន មានតម្លៃជាទឹកប្រាក់ ជាង

៤០ ០០០ដុល្លារអាមេរិក

**ខ. មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ទឹកប្រាក់ ២ ០០០ ដុល្លារអាមេរិក

២-ឯកឧត្តម **អ៊ឹង អឿន** អភិបាលរងទី១ ខេត្តសៀមរាប

ទឹកប្រាក់ ១ ១០០ ដុល្លារអាមេរិក

៣-ព្រះគ្រូធម្មចរិយាចារ្យ **ហេង ស៊ីថុង** ព្រះចៅអធិការវត្ត ខ្មែរសារីរតនារាម

រដ្ឋហ្វ្លរីដា សហរដ្ឋអាមេរិក

៤-ព្រះគ្រូចៅអធិការធម្មចក្ការាម **ឃុន ហ៊ួត** រដ្ឋវ៉ាស៊ីនតោនស្ទេទ សហរដ្ឋអាមេរិក

៥-លោក **ខឹន តារា** ទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណមហានិកាយ

រដ្ឋកាលីហ្វញ៉ា សហរដ្ឋអាមេរិក

៦-ឧបាសិកា **ឌួន ម៉ុំ** រដ្ឋកាលីហ្វញ៉ា សហរដ្ឋអាមេរិក

៧-ឧបាសិកា **អ៊ឹង ពុំសុខា** ភ្នំពេញ

៨-លោក **ជួម សាវឿ** រដ្ឋកាលីហ្វញ៉ា សហរដ្ឋអាមេរិក

| | | |
|---|---|---|
| ៩-ឧបាសក | មុី ហ៊ុយអេង | ប្រធានសមាគមព្រះពុទ្ធសាសនារដ្ឋកាលីហ្វញ៉ា |
| ១០-លោកស្រី | ឡឹម ឡេងគី | កាណាដា |
| ១១-លោក | គោស៊ុំ សារឿត | នាយកមន្ទីរទេសចរណ៍ខេត្ត |
| | | ទឹកប្រាក់ ២ ០០០ ដុល្លារអាមេរិក |
| ១២-ឧបាសិកា | នូរ ស៊ន | ប្រជាជន ខេត្ត សៀមរាប |
| | | ទឹកប្រាក់ ២ ០០០ ដុល្លារអាមេរិក |
| ១៣-លោក | គី អួន | ប្រជាជន ខេត្ត សៀមរាប |
| | | ទឹកប្រាក់ ២ ០០០ ដុល្លារអាមេរិក |
| ១៤-ឧបាសក | ជា ជួយ | ប្រជាជន ខេត្ត សៀមរាប |
| | | ទឹកប្រាក់ ១ ៥០០ ដុល្លារអាមេរិក |
| ១៥-ឧបាសិកា | រី គីមឈង់ | ប្រជាជន ខេត្ត សៀមរាប |
| | | ទឹកប្រាក់ ១ ៥០០ ដុល្លារអាមេរិក |
| ១៦-ឧបាសិកា | អ៊ឹង ស៊ីវអ៊ាង | ប្រជាជន ខេត្ត សៀមរាប |
| | | ទឹកប្រាក់ ១ ៥០០ ដុល្លារអាមេរិក |

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងអភិបាលខេត្ត សៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

# អនុក្រឹត្យ លេខ ២៩ អនក្រ.តត
# ស្តីពី
# ការតម្លើងឋានន្តរសក្តិនាយទាហាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពល ខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១** .- ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនសពវរសេនីយ៍ទោ **រស់ សារ៉ាវិទ្ធ** អត្តលេខ ០០៣៣៣៣ នាយរងការិយាល័យទី២ កងឯកភាពអង្គរក្សសម្តេច **ហ៊ុន សែន** ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែល

ពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

~ ~ ~

## អនុក្រឹត្យ លេខ ៣០ អនក្រ.តត
## ស្តីពី
## ការតម្លើងឋានៈ មន្ត្រីរាជការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតំរូវការការងារ របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១** .- ត្រូវបានតម្លើងឋានៈស្មើ **អគ្គនាយករង** ជូនពិធីការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០៣រូប ដូចមានរាយនាមខាងក្រោម :

-លោកស្រី **ទ្រី សុខា**

-លោក **រស់ ច័ន្ទផល្លី**

-លោក **សុខ សុរិយា**

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

~ ~ ~

## ២-សេចក្តីសំរេច

## សេចក្តីសំរេច លេខ ០៤ សសរ

## ស្តីពី

## ការប្រគល់ទីតាំង និងអាគារសាលាមធ្យមសិក្សាពាណិជ្ជកម្ម និង មជ្ឈមណ្ឌលកុមារកំព្រាលេខ ៣

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

**សំរេច**

**ប្រការ ១** : ប្រគល់ដី និងអាគារវិទ្យាល័យភាសាបារាំង នៅភ្នំពេញ ( បច្ចុប្បន្ន សាលាមធ្យមសិក្សាពាណិជ្ជកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា) អោយទៅរដ្ឋាភិបាលបារាំងគ្រប់គ្រង ដែលជាថ្នូរទៅនិងការផ្តល់វិភាគទានសំរាប់ការសាងសង់ឡើងវិញ នូវអាគារសាលាមធ្យមសិក្សាពាណិជ្ជកម្ម ។

**ប្រការ ២** : ប្រគល់ទីតាំងអាគារនិងដីមជ្ឈមណ្ឌលកូឡាបទី៣ ស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានផ្ទៃក្រឡាចំនួន ៦៤៥២.២៦ ម៉ែត្រក្រឡា អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់ការងារសាងសង់សាលាមធ្យមសិក្សា ពាណិជ្ជកម្ម ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថ លេខាតទៅ ។

ភ្នំពេញ.ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## សេចក្តីសំរេច លេខ ០៥ សសរ

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ការនាំចូលតាមច្រកព្រំដែននូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ

-\-

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់នូវការនាំចូលតាមច្រកព្រំដែននានា នូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគ ដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ហុង ស៊ុនហួត** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាប្រធាន |
| ២-ឯកឧត្តម **ចំរូន តុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | អនុប្រធាន |
| ៣-ឯកឧត្តម **សុក ស៊ីផាន់ណា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤-ឯកឧត្តម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៥-ឯ.ឧ ឧត្តមសេនីយទោ **នេត សាវឿន** | ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | សមាជិក |
| ៦-ឯ.ឧ ឧត្តមសេនីយត្រី **តេខ ឈួន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៧-ឯកឧត្តម | អភិបាលខេត្ត ដែលមានការពាក់ព័ន្ធ | សមាជិក |

**ប្រការ ២** : គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

- ស្រាវជ្រាវ និងត្រួតពិនិត្យ អោយបានហ្មឹងម៉ាត់ការនាំចូលតាមបណ្តាច្រកព្រំដែននូវសត្វរស់ ផលិត ផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគគ្រប់ប្រភេទសំដៅថែរក្សាការពារ **និង លើកកំពស់សុខភាព សាធារណៈ ។**

- លើកវិធានការទប់ស្កាត់តាមផ្លូវច្បាប់អោយមានប្រសិទ្ធភាពនូវការនាំចូលសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគគ្រប់ប្រភេទដែលខូចគុណភាព និងផ្ទុកទៅដោយមេរោគឆ្លង ដែលបណ្តាលអោយប៉ះពាល់ដល់សុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ ។
- ចំពោះមុខត្រូវធ្វើការទប់ស្កាត់ជាបន្ទាន់នូវការនាំចូលសត្វជ្រូក និងគោដែលមានជម្ងឺឆ្កួតជាដើម ។
- ស្រាវជ្រាវរកអោយឃើញនូវបុគ្គលដែលបាននាំចូលសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគដែលខូចគុណភាព និងមានមេរោគឆ្លង និងមុខសញ្ញាដែលមានការពាក់ព័ន្ធ ដើម្បីបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។
- ចាត់វិធានការរឹបអូស និងបំផ្លាញចោលមុខទំនិញខូចគុណភាព និងមានមេរោគឆ្លង ដែលបាននាំចូល ។
- ធ្វើរបាយការណ៍លំអិតជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្តបាន និងស្នើសុំយោបល់សំរេចពីរាជរដ្ឋាភិបាល ក្នុងករណីមានការចាំបាច់ ។

**ប្រការ ៣** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិរៀបចំលេខាធិការដ្ឋានមួយ ដើម្បីជំនួយការងារដែលមានទីតាំង និងសមាសភាពកំណត់ដោយឯកឧត្តមប្រធានគណៈកម្មការ និងមានសិទ្ធិប្រើប្រាស់របស់ក្រសួងសុខាភិបាល ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាភាពដូចមានចែង ក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

៖ ៖ ៖

# សេចក្តីសំរេច លេខ ០៦ សសរ

## ស្តីពី

## ការបង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ

~~~

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងស្មារតីនៃជំនួបមិត្តភាពក្រៅផ្លូវការនៅវៀងច័ន្ទ រវាងនាយករដ្ឋមន្ត្រី កម្ពុជា-វៀតណាម-ឡាវ នាថ្ងៃ ១៩-២០ តុលា ១៩៩៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ ដែលមានសមាសភាពដូចតទៅ :

១-លោកជំទាវ **ស៊ុន សារឿន** អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាន

២-លោក **លាត ទណ្ឌជេន** អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣-លោក **ឡុង គែម** ប្រធាននាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ក្រសួងការបរទេស អនុប្រធានអចិន្ត្រៃយ៍

៤-លោក **លឹម សំកុល** ប្រធាននាយកដ្ឋានទំនាក់ទំនង អន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
~~~

៥-លោក **នុត ចន្ទសុខា** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិក្រសួងផែនការ សមាជិក

៦-លោក **ទ៉ា ស៊ីមសុរិយ៉ា** ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៧-លោក **សុខ សុតំគ្រា** ប្រធាននាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម សមាជិក

៨-លោក **ម៉ុខ ណារិទ្ធ** ប្រធាននាយកដ្ឋានរ៉ែអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៩-លោក **សៅ ជ័យចន្ទ** ប្រធានស្តីទីនៃនាយកដ្ឋានផែនការនិងទំនាក់ទំនងអន្តរជាតិ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១០-លោក **សារ ណារាក់** អនុប្រធាននាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១១-លោក **នួត សារ៉ាវុធ** អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២-លោកវេជ្ជបណ្ឌិត **ឡូ វាសនាគីរី** អនុប្រធាននាយកដ្ឋានផែនការស្ថិតិ ផែនការនិងពត៌មានសុខាភិបាលក្រសួងសុខាភិបាល សមាជិក

**ប្រការ ២** : គណៈកម្មការនេះ មានបេសកកម្មដូចខាងក្រោម :

- សិក្សាស្រាវជ្រាវ និងពិចារណាធ្វើយ៉ាងណាដើម្បីអភិវឌ្ឍន៍តំបន់ត្រីកោណ រវាងប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ លើផ្នែកបរិស្ថាន កសិកម្ម និងរចនាសម្ព័ន្ធផ្លូវគមនាគមន៍ ។
- រិះរកមធ្យោបាយយ៉ាងណា ក្នុងការធ្វើអោយប្រសើរឡើង នូវការផ្លាស់ប្តូរពាណិជ្ជកម្ម រវាងប្រទេសទាំងបី ក្នុងតំបន់ត្រីកោណនេះ ។
- រិះរកមធ្យោបាយ អភិវឌ្ឍន៍វិស័យទេសចរណ៍ នៅប្រទេសទាំងបី ។
- រិះរកមធ្យោបាយធ្វើយ៉ាងណា ដើម្បីទប់ស្កាត់ជនអន្តោប្រវេសន៍ខុសច្បាប់ ។
- ពង្រឹងការឯកភាពគ្នា ក្នុងកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌប្រទេសអាស៊ាន ។

- ពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់ ការរត់ពន្ធគ្រឿងញៀន និងប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ។

**ប្រការ ៣** : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ច និងសិទ្ធិ :

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារកម្មវិធីនៃសកម្មភាព ក្នុងការគ្រប់គ្រង និងជំរុញកិច្ចសហប្រតិបត្តិការ ក្នុងទិសដៅអភិវឌ្ឍន៍តំបន់ត្រីកោណ តាមព្រំដែនប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ ។
- ចូលរួមប្រជុំ និងធ្វើទំនាក់ទំនងផ្ទាល់ ជាមួយក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ ខាងភាគីវៀតណាម និងឡាវ និងអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយការងារពាក់ព័ន្ធ ។
- បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលរដ្ឋាភិបាលនៃភាគីទាំងបីបានឯកភាពគ្នា ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំ និងគោលការណ៍ សំរេច ។

**ប្រការ ៤** : សមាជិកក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ ត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងក្រោមការដឹកនាំរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន ។ ក្នុងករណីសមាជិកណាម្នាក់មិនបានអញ្ជើញចូលរួមប្រជុំ ដោយជាប់រវល់ភារកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេច អោយចូលរួមជំនួស ។

**ប្រការ ៥** : ក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ មានលេខាធិការដ្ឋាន ដែលមានទីតាំងនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយមានសិទ្ធិប្រើប្រាស់ត្រាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេសមកពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អោយចូលរួមប្រជុំ ឬជួយបំពេញការងារក្នុងឋានៈជាជំនួយការ ខាងផ្នែកបច្ចេកទេស ។ លេខាធិការដ្ឋាននៃក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណនេះ ត្រូវដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍នៃក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង សុខាភិបាល និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

## ៣_សារាចរ

## សារាចរណែនាំ លេខ ០១ សរណន

## ស្តីពីការរៀបចំ បែបបទស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ក្នុងការការពារ និងកសាងប្រទេស រាជរដ្ឋាភិបាលធ្លាប់បានបំពាក់នូវគ្រឿងឥស្សរិយយសរបស់ជាតិគ្រប់ប្រភេទ ជូនចំពោះជនរួមជាតិ និងមិត្តភក្តិបរទេស ស្របទៅតាមទំហំស្នាដៃ និងគុណបំណាច់របស់បុគ្គលម្នាក់ៗ ឬសមូសភាពនិមួយៗ ។ គោលនយោបាយលើកទឹកចិត្ត និងផ្តល់កិត្តិយសខាងលើនេះ ត្រូវបានទទួលការអបអរសាទរពីគ្រប់មជ្ឈដ្ឋាន ។ ទន្ទឹមនឹងលទ្ធផលដ៏ល្អខាងលើនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា នៅមានការខ្វះចន្លោះមួយចំនួនដែលចាំបាច់ត្រូវមានការកែលំអឡើងវិញ ដើម្បីអោយការផ្តល់គ្រឿងឥស្សរិយយស

របស់ជាតិមានភាពត្រឹមត្រូវ យុត្តិធម៌ និងរក្សាបាននូវមោទនភាពដ៏ខ្ពង់ខ្ពស់របស់ជាតិយើង ស្របតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ ៦៦/អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីបង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន អំពីបែបបទនៃការស្នើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ ដូចមានខ្លឹមសារខាងក្រោមនេះ :

១- ដើម្បីរក្សាតំលៃគ្រឿងឥស្សរិយយសរបស់ជាតិ និងដើម្បីអោយរបៀបរបបការងាររដ្ឋបាលដំណើរការបានល្អ រាល់សំណើសុំគ្រឿងឥស្សរិយយសទាំងអស់ចាំបាច់ត្រូវឆ្លងកាត់គណៈកម្មការពិនិត្យ លក្ខណៈសម្បត្តិវរជនដែលត្រូវស្នើគ្រឿងឥស្សរិយយសរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងអនុក្រឹត្យលេខ ៦៦/អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ក្រោយធ្វើសារាចរណែនាំចូលជាធរមាន ។

២- គ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចបង្កើតអោយមាន "គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស" មួយដែលមានថ្នាក់ដឹកនាំក្រសួង-ស្ថាប័នផ្ទាល់ជាប្រធានគណៈកម្មការ និងថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួង-ស្ថាប័នជាសមាជិក ។ គណៈកម្មការនេះមានភារកិច្ចពិនិត្យ លក្ខណៈសម្បត្តិវរជន មន្ត្រីរាជការ ក្រោមឱវាទសំរាប់ជ្រើសរើសជាបេក្ខជនស្នើសុំគ្រឿងឥស្សរិយយសទៅតាមប្រភេទ និងវិស័យការងារ ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា ដែលមានជូនភ្ជាប់មកជាមួយនេះស្រាប់ ក្រោយពេលគណៈកម្មការពិនិត្យជ្រើសរើស និងមានការឯកភាពពីប្រធានស្ថាប័នរួចហើយ ក្រសួង-ស្ថាប័នត្រូវធ្វើសំណើ និងបញ្ជីឈ្មោះបេក្ខជនដោយភ្ជាប់មកជាមួយនូវ កំណត់ហេតុប្រជុំវាយតម្លៃរបស់គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិផង រួចហើយផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងដាក់ជូន រាជរដ្ឋាភិបាលសំរេច ។

៣- វរជន មន្ត្រីរាជការ ដែលជ្រើសរើសជាបេក្ខជនត្រូវមានលក្ខណៈសម្បត្តិធំៗ ៥ ចំណុចដូចខាងក្រោម :

ក- សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និងសកម្មភាពផ្ទុយពីច្បាប់រដ្ឋ ។

ខ- គំនិតផ្តួចផ្តើម និងមនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ថ្លៃប្រឌិត និងទទួលខុសត្រូវ ។

គ-ការដឹកនាំនិងគ្រប់គ្រងមានប្រសិទ្ធភាព ។

ឃ-ស្មារតីស្នេហាជាតិ គិតគូដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់ក្រសួង-ស្ថាប័ន ។

ង-សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជន ។

ផ្អែកតាមលក្ខណសម្បត្តិធំៗខាងលើ គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិរបស់ក្រសួង-ស្ថាប័ននិមួយៗ ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យជាក់ស្តែង ស្របតាមវិស័យការងាររបស់ស្ថាប័នរៀង១ខ្លួន ។

៤-វីរជន មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ដែលបំរើការនៅតាមក្រសួង ស្ថាប័ន ហើយបានពិនិត្យជ្រើសរើសជាបេក្ខជន ដើម្បីស្នើផ្តល់គ្រឿងឥស្សរិយយស ចាំបាច់ត្រូវគិតទៅតាមទំហំស្នាដៃ និងឆ្លាស់វេនរយៈពេល០២ឆ្នាំម្តង ។

៥-ចំនួនបេក្ខជនប្រចាំឆ្នាំ នៃបណ្តាក្រសួង-ស្ថាប័ននិមួយៗ ដែលស្នើសុំគ្រឿងឥស្សរិយយស ត្រូវកំណត់មិនអោយលើសពី១០ភាគរយ នៃចំនួនក្របខ័ណ្ឌសរុបរបស់ក្រសួង-ស្ថាប័នឡើយ ។ ក្នុងចំនួនសមាមាត្រ១០ភាគរយនេះ ត្រូវជ្រើសរើសពីក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ០២ភាគរយ. មន្ត្រីក្របខ័ណ្ឌក្រមការ ០៣ ភាគរយ និងក្របខ័ណ្ឌលេខាធិការ ចំនួន ០៥ភាគរយ ។

៦-ចំនួនបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមខ្ពស់ ត្រូវអោយតិចជាងចំនួនបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមទាបជាង ។ ក្នុងជំហានដំបូងត្រូវស្នើសុំគ្រឿងឥស្សរិយយសថ្នាក់ទាបសិន មុននឹងឈានទៅដល់ថ្នាក់ខ្ពស់ជាបន្តបន្ទាប់ ។ បេក្ខជនដែលជ្រើសរើសសំរាប់ស្នើសុំគ្រឿងឥស្សរិយយស ក្នុងស្ថាប័ននិមួយៗ គឺគិតតែក្នុងក្របខ័ណ្ឌមុខងារសាធារណៈតែប៉ុណ្ណោះ ។

ចំពោះមន្ត្រីថ្នាក់ដឹកនាំដែលជាសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ មិនត្រូវបញ្ចូលមកក្នុងបញ្ជីស្នើសុំគ្រឿងឥស្សរិយយស របស់មន្ត្រី រាជការមុខងារសាធារណៈនេះទេ គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវីរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស របស់រាជរដ្ឋាភិបាល និងរៀបចំជូនក្នុងបញ្ជីមួយដោយឡែក។

៧-វីរជន មន្ត្រីរាជការ ដែលបំពេញការងារក្នុងវិស័យនិមួយៗ អាចនឹងទទួលបានគ្រឿងឥស្សរិយយសផ្សេងខុសពីមុខជំនាញរបស់ខ្លួន ប្រសិនជាស្នាដៃ និងគុណបំណាច់នោះបំរើអោយវិស័យដទៃទៀត ។ ក្នុងករណីនេះ ប្រធានស្ថាប័នជំនាញ ដែលទទួលបានផលប្រយោជន៍ពីស្នាដៃ និងគុណបំណាច់ខាងលើ ជាអ្នកធ្វើសំណើសុំមកទីស្តីការគណៈរដ្ឋមន្ត្រី ក្រោយពីពិភាក្សាឯកភាពជាមួយស្ថាប័នដែលគ្រប់គ្រងបេក្ខជនផ្ទាល់ ។

-ក្រសួងការពារជាតិ ជាអ្នកធ្វើសំណើសុំគ្រឿងឥស្សរិយយស ជូននាយទាហាន នាយទាហានរងពលទាហាន និងកងឯកភាពនៃកងយោធពលខេមរភូមិន្ទ ក្រោយពីបានទទួលសំណើតាមឋានានុក្រមពីអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទរួចមក ។

-ក្រសួងស្ថាប័នជំនាញថ្នាក់កណ្តាល និងអាជ្ញាធរមូលដ្ឋានត្រូវមានការឯកភាពគ្នា មុននឹងស្នើសុំគ្រឿងឥស្សរិយយសជូនបេក្ខជន ដែលជាមន្ត្រីរាជការជំនាញនៅមូលដ្ឋាន ដោយក្រសួង-ស្ថាប័ន ជាអ្នកធ្វើសំណើ ។

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យវាយតម្លៃការងាររបស់បណ្តាបុគ្គលិក អង្គទូត និងតំណាងប្រទេសជាមិត្ត ព្រមទាំងតំណាងអង្គការអន្តរជាតិនានា ដែលមកបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានស្នាដៃ និងគុណបំណាច់ល្អប្រសើរ បំរើរោយផលប្រយោជន៍ប្រជារាស្ត្រខ្មែរ ដើម្បីស្នើសុំបំពាក់មេដាយសហមេត្រីតាមលំដាប់ថ្នាក់ មុនពេលបញ្ចប់អណត្តិនិមួយៗ ដោយគិតចាប់ពី ៣ឆ្នាំឡើងទៅ ហើយក៏ត្រូវឯកភាពយល់ព្រមពីភាគីមិត្តជាមុនសិនដែរ មិននឹងស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី ។

៨-ដើម្បីអោយស្របតាមព្រះរាជក្រឹត្យ និងអនុក្រឹត្យ លេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ចំពោះបែបបទនៃកាស្នើសុំមេដាយស្ថាបនាជាតិ ដែលបានអនុវត្តកន្លងមកត្រូវរក្សាការអនុវត្តន៍ដដែល ដោយគ្រាន់តែប្តូរឈ្មោះពី :

-មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ទៅជា មេដាយមាសស្ថាបនាជាតិ

-មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ទៅជា មេដាយប្រាក់ស្ថាបនាជាតិ

-មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ទៅជា មេដាយសំរិទ្ធស្ថាបនាជាតិ

មេដាយស្ថាបនាជាតិនេះ សំរាប់បំពាក់ជូនតែសប្បុរសជនដែលបានបរិច្ចាគធនធានរបស់ខ្លួនពិតប្រាកដតែប៉ុណ្ណោះ ។ ចំពោះមន្ត្រីរាជការដែលពាក់ព័ន្ធជាមួយសប្បុរសជន ឬជាអ្នកទាក់ទាញអំណោយពីសប្បុរសជន មិនត្រូវបានទទួលមេដាយខាងលើនេះឡើយ ។

៩-រាល់សំណើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ របស់ក្រសួង-ស្ថាប័ន លុះត្រាតែប្រមុខរាជរដ្ឋាភិបាលចុះហត្ថលេខាលើអនុក្រឹត្យ ឬ ព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ ទើបទីស្តីការគណៈរដ្ឋមន្ត្រីបើកគ្រឿងឥស្សរិយយសជូនបាន លើកលែងតែក្នុងករណីពិសេស បន្ទាន់ និងចាំបាច់ នាយករដ្ឋមន្ត្រី ស្នើរៀបចំពិធីបំពាក់ជាមុន ទើបធ្វើបែបបទស្នើសុំជាក្រោយ ។

១០-គ្រឿងឥស្សរិយយសគ្រប់ប្រភេទ គ្រប់លំដាប់ថ្នាក់ដែលវរជន មន្ត្រីរាជការម្នាក់ៗបានទទួលត្រូវកត់ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួន ហើយត្រូវបានយកមកថ្លឹងថ្លែងជាគុណសម្បត្តិសំរាប់ការពិចារណា តម្លើងថាននន្តរសក្តិ ។

១១-គ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យវាយតម្លៃស្នាដៃឆ្នាំ២០០០ ជូនមន្ត្រីរាជការក្រោមឱវាទ រួចបញ្ជូនសំណើមកទីស្តីការគណៈរដ្ឋមន្ត្រី អោយបានមុនថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០១ ដើម្បីបូកសរុប ពិនិត្យ និងសំរេច ជូននាឱកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ ។ សំណើណាដែលមកក្រោយការកំណត់ខាងលើនេះ នឹងមិនត្រូវបានយកមកដោះស្រាយឡើយ ។

១២-បណ្តាក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលមានគំរោងស្នើសុំ គ្រឿងឥស្សរិយយសត្រូវបញ្ជូនសំណើ និងបញ្ជីឈ្មោះបេក្ខជនអោយបានមកដល់ទីស្តីការគណៈរដ្ឋមន្ត្រី យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនិមួយៗ ដើម្បីអាចបូកសរុប ពិនិត្យ និងសំរេច ជូន គ្រឿងឥស្សរិយយស នាឱកាសដំណាចឆ្នាំ ។

សារាចរណែនាំ លេខ ០៧ សរណន ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧ ត្រូវទុកជានិរាករណ៍ ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់ថា គ្រប់ក្រសួង-ស្ថាប័ន គ្រប់ជាន់ថ្នាក់ នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ យុត្តិធម៌ ត្រឹមត្រូវ ស្មើភាព សំដៅរក្សាអោយបាននូវសុក្រឹតភាព និងតម្លៃ នៃ គ្រឿងឥស្សរិយយសរបស់ជាតិ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

៚

# III- ការងារបណ្ដាក្រសួង

## ទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សេចក្ដីប្រកាស

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

### សេចក្ដីប្រកាស លេខ ០២២ សប្រក.កសក

### ស្ដីពី

### ការហាមឃាត់រាល់សកម្មភាពអាជីវកម្ម ពាណិជ្ជកម្មព្រៃឈើ ការកាប់រានដីព្រៃ និងការបរបាញ់សត្វព្រៃក្នុងតំបន់ជួរភ្នំក្រវាញភាគកណ្ដាល

ដោយផ្អែកតាមលទ្ធផលរបាយការណ៍ ចុះសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់ សហការជាមួយអង្គការមូលនិធិសត្វខ្លា (CAT) ឆ្នាំ ១៩៩៨ អង្គការរុក្ខជាតិអន្តរជាតិ (FFI) ឆ្នាំ ១៩៩៩ និង ២០០០ បានបង្ហាញយ៉ាងច្បាស់ថា តំបន់ជួរភ្នំក្រវាញពិតជាមានសក្ដានុពលខ្ពស់សំរាប់ការអភិរក្សជីវចំរុះដូចជា : សត្វចតុប្បាទ (សត្វខ្លាធំ ខ្លាឃ្មុំ ដំរី ....) ឧរង្គសត្វ ក្រពើ ពស់ បង្កួយ ......បក្សីសត្វ និងប្រភេទរុក្ខជាតិមានដោយកម្រផ្សេងៗទៀត ព្រមទាំងប្រព័ន្ធផ្លូវទឹក និង បណ្ដាតំបន់ទឹកជ្រោះដ៏មានតំលៃធំធេងដែលរួមផ្សំគ្នាបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីមួយដ៏ប្រណិត ។ ទន្ទឹមនឹងនេះដែរផ្អែកតាមរបាយការណ៍របស់គំរោងត្រួតពិនិត្យ និងតាមដានឧក្រិដ្ឋកម្មព្រៃឈើ បានបញ្ជាក់ថា ភាពអនាធិបតេយ្យ ក្នុងការធ្វើអាជីវកម្មព្រៃឈើ និងការលួចបរបាញ់សត្វព្រៃក្នុងជុំវិញតំបន់នោះបាននឹងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ។ ការបាត់បង់ព្រៃឈើអាចនឹងជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើតុល្យភាពប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងជីវសាស្ត្រចំរុះក្នុងប្រទេសកម្ពុជា និងដោយការមើលឃើញនូវភាពចាំបាច់ និងតួនាទីដ៏មានសារៈសំខាន់របស់តំបន់ភាគកណ្ដាលនៃជួរភ្នំក្រវាញ ក្នុងការថែរក្សាលំនឹងបរិស្ថានធម្មជាតិ ជាពិសេស ដើម្បីការពារនូវពពួកសត្វព្រៃមួយចំនួនដែលកំពុងទទួលរងនូវការគំរាមកំហែងស្ទើរលត់ផុតពូជពីលើភពផែនដី ប៉ុន្តែកំពុងមានវត្តមានក្នុងតំបន់នេះ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើសេចក្ដីប្រកាសដូចតទៅ :

១-កំណត់តំបន់ជួរភ្នំក្រវាញភាគកណ្តាល ជាតំបន់សិក្សាស្រាវជ្រាវ ដើម្បីកំណត់ទិសដៅ និងផែនការគ្រប់គ្រងអភិរក្សជីវចំរុះ និងភាពបរិសុទ្ធនៃធម្មជាតិ ។

២-កំណត់តំបន់ជួរភ្នំក្រវាញភាគកណ្តាលនេះមានផ្ទៃដីសរុបចំនួន ៣៣០.៩២៣ ហិកតា មានព្រំប្រទល់ដូចបានកំណត់នៅលើផែនទីជូនភ្ជាប់ជាមួយនេះ ។

៣-ហាមដាច់ខាតរាល់សកម្មភាពអាជីវកម្ម ពាណិជ្ជកម្មព្រៃឈើ ការកាប់រានដីព្រៃឈើ ការរុករាន ការបំផ្លាញព្រៃឈើ និងការបរបាញ់សត្វព្រៃនៅតំបន់ជួរភ្នំក្រវាញភាគកណ្តាលនេះ ។

៤-មិនហាមឃាត់ និងប៉ះពាល់ដល់សិទ្ធិរបស់ប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ជួរភ្នំក្រវាញ ដើម្បីប្រមូលអនុផលព្រៃឈើសំរាប់ប្រើប្រាស់ និងតម្រូវការនៅមូលដ្ឋានទេ ។

៥ ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ដែលមានផ្ទៃដីស្ថិតនៅក្នុងតំបន់សិក្សានេះ ត្រូវផ្អាកជាបណ្តោះអាសន្នរាល់គ្រប់សកម្មភាពអាជីវកម្មព្រៃ ដើម្បីផ្តល់លទ្ធភាពដល់ការសិក្សាស្រាវជ្រាវលំអិត ។

៦ ព្រំប្រទល់តំបន់ព្រៃឈើនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើលទ្ធផល ពិតមានវិទ្យាសាស្ត្រ និងស្ថានភាពចាំបាច់ជាក់ស្តែងនាពេលអនាគត ។

ក្រោយពីទទួលសេចក្តីប្រកាសនេះ គ្រប់អង្គភាពនៅថ្នាក់កណ្តាល ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ការិយាល័យរុក្ខា-ប្រមាញ់ ខេត្តពោធិសាត់ កោះកុង និង កំពង់ស្ពឺ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ខិតខំអនុវត្តន៍សេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ច័ន្ទ សុខអ៊ីវ**

≈≈≈≈